ខ្មែរ|

ច្បាប់
ស្តីពី
នីតិវិធី
នៃការពិន័យស៊ីវិល

ទាញយកឯកសារច្បាប់និងបទប្បញ្ញត្តិផ្សេងៗពី
គេហទំព័រក្រសួងយុត្តិធម៌តាមរយៈអសយដ្ឋាន
www.moj.gov.kh

ចូលរួមក្នុងបណ្តាញសង្គមរបស់ក្រសួង/Join Our Social Media
t.me/mojcambodia
fb.com/mojcambodia

០១១

៣១ មីនា ២០០៨

នស/រកម/០៣០៨/០១១

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE
ACTES ROYAL

ច្បាប់

ស្តីពី

នីតិវិធីនៃការពិន័យស៊ីវិល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

3/6

www.moj.gov.kh

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.- គោលបំណង

ច្បាប់នេះកំណត់អំពីនីតិវិធីនៃការពិន័យស៊ីវិល ដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ដែលចែងអំពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ។

មាត្រា ២.- ការអនុវត្តជាសកល

បញ្ញត្តិនៃច្បាប់ដែលចែងអំពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការពិន័យស៊ីវិល លើកលែងតែករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់នេះ ។

ជំពូកទី ២
សមត្ថកិច្ច

មាត្រា ៣.- សមត្ថកិច្ច

រឿងក្តីពិន័យស៊ីវិល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលបានកំណត់ នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅ តាមលំនៅឋាន ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ភាគីនៃនីតិវិធីនៃការពិន័យស៊ីវិលនោះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេង ។

ជំពូកទី ៣
នីតិវិធី

មាត្រា ៤.- ការចាប់ផ្តើមនីតិវិធី

នីតិវិធីនៃការពិន័យស៊ីវិល ត្រូវចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់តុលាការ ។

មាត្រា ៥.- នីតិវិធីនៃការវិនិច្ឆ័យអំពីការពិន័យស៊ីវិល

១-ការសម្រេចសេចក្តីអំពីការពិន័យស៊ីវិល ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុ និង សេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើលិខិតដីកាសម្រេចនេះ ។

៣-ដើម្បីចេញដីកាសម្រេចអំពីការពិន័យស៊ីវិល តុលាការត្រូវសួរមតិយោបល់ពីតំណាងអយ្យការ និង ស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី ជាមុន ។

៤-ចំពោះដីកាសម្រេចអំពីការពិន័យស៊ីវិល តំណាងអយ្យការ និង ភាគីអាចប្តឹងជំទាស់បាន ។ ដីកាសម្រេចដាក់ពិន័យស៊ីវិល មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

៥-ក្នុងករណីដែលបានចេញដីកាសម្រេចដាក់ពិន័យស៊ីវិល ប្រាក់ប្រដាប់ក្តីតុលាការដែលចាំបាច់សម្រាប់នីតិវិធីនៃដីកាសម្រេចអំពីការពិន័យស៊ីវិល រួមទាំងនីតិវិធីនៃការវិនិច្ឆ័យអំពីបណ្តឹងជំទាស់ គឺជាបន្ទុករបស់បុគ្គលដែលទទួលដីកាសម្រេចនោះ ហើយក្រៅពីករណីនេះ គឺជាបន្ទុករបស់រដ្ឋ ។

៦-ក្នុងករណីដែលមានបណ្តឹងជំទាស់ពីភាគី ចំពោះដីកាសម្រេចដាក់ពិន័យស៊ីវិល ប្រសិនបើតុលាការនៃបណ្តឹងជំទាស់ លុបចោលនូវដីកាសម្រេចដើម ហើយចេញដីកាសម្រេចថ្មី អំពីការពិន័យស៊ីវិល ទោះបីជាដីកាសម្រេចនេះ ជាដីកាសម្រេចដាក់ពិន័យស៊ីវិលក៏ដោយ ក៏ប្រាក់ប្រដាប់ក្តីតុលាការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះគឺជាបន្ទុករបស់រដ្ឋដែរ ។

មាត្រា ៦.- ការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល

១-ដីកាសម្រេចដាក់ពិន័យស៊ីវិល ត្រូវអនុវត្តដោយការបង្គាប់របស់តំណាងអយ្យការ ។ ការបង្គាប់នេះមានអានុភាពដូចគ្នានឹងលិខិតអនុវត្តដែលមានរូបមន្តអនុវត្ត ។

២-ការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល ត្រូវធ្វើដោយអនុលោមតាមគន្ថីទី ៦នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីនីតិវិធីនៃការអនុវត្ត ដោយពុំចាំបាច់ធ្វើការបញ្ជូនដីកាសម្រេច មុនពេលអនុវត្តឡើយ ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

៣-ប្រសិនបើយល់ឃើញថាចាំបាច់ ដើម្បីធ្វើការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល តំណាងអយ្យការអាចស្នើរទៅស្ថាប័នរដ្ឋ ឬ អង្គភាពសាធារណៈ ឬ អង្គភាពឯកជន ឱ្យធ្វើរបាយការណ៍អំពីចំណុចដែលចាំបាច់បាន ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ៧_ ការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៨

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៣០៨.០១០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្សវឌ្ឍនា

លេខ ៣៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

6/6